ពាក្យប្រើប្រាស់ទាក់ទងនឹង**មិត្តភក្តិ**

បញ្ជីពាក្យខាងក្រោមត្រូវបានគេប្រើប្រាស់ជាញឹកញាប់ក្នុងចំណោមមិត្តភក្តិ (បណ្តាជនដែលមានពិការភាព)។ បញ្ជីពាក្យនេះជួយអ្នកឱ្យយល់អ្វីដែលយើងចង់និយាយ។

## 1. Peer

| | |
|---|---|
| សេចក្តីបកប្រែ | មិត្តភក្តិ |
| ការពន្យល់ខ្លីៗពីអត្ថន័យ | មិត្តភក្តិគឺជាអ្នកជំនាញការម្នាក់នៅក្នុងជីវិតរបស់គាត់។<br>មិត្តភក្តិគឺជាជនម្នាក់ដែលមានបទពិសោធន៍ក្នុងជីវិតផ្នែកពិការភាព។<br>មិត្តភក្តិមានឋានៈស្មើគ្នា។<br>មិត្តភក្តិចែករំលែកចំណេះដឹងនិងបទពិសោធន៍របស់ខ្លួនទៅវិញទៅមក។ |
| ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រើប្រាស់ពាក្យនេះ | ▪ មិត្តភក្តិពីរនាក់ជួបគ្នានៅក្នុងហាងកាហ្វេមួយដើម្បីចែករំលែកនូវអ្វីដែលខ្លួនដឹងអំពីការគ្រប់គ្រងផែនការអិនឌីអាយអេស (NDIS) ដោយខ្លួន ឯង។<br><br>▪ មិត្តភក្តិមួយក្រុមជួបជុំគ្នាដើម្បីចែករំលែកនូវបទពិសោធន៍របស់ខ្លួនក្នុងការរកបុគ្គលិកផ្នែកគាំទ្រ (support Worker) ។<br>ម្នាក់ៗរៀនពីគ្នាទៅវិញទៅមក។ |

| | |
|---|---|
| | |

## 2. Peer Facilitator

| | |
|---|---|
| សេចក្តីបកប្រែ | អ្នកសម្រួលកិច្ចការរវាងមិត្តភក្តិ |
| ការពន្យល់ខ្លីៗពីអត្ថន័យ | មិត្តភក្តិម្នាក់ដែលជួយមិត្តភក្តិម្នាក់ទៀត<br>ឬមិត្តភក្តិមួយក្រុមឱ្យរៀន ឬយល់ដឹងនូវអ្វីដែលថ្មី។<br>មិត្តភក្តិម្នាក់ដែលជួយនិងណែនាំមនុស្សមួយក្រុមឱ្យមានការសន្ទនា និងរៀនពីគ្នាទៅវិញទៅមក។ |
| ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រើប្រាស់ពាក្យនេះ | ▪ មិត្តភក្តិមួយក្រុមជួបជុំគ្នាដើម្បីរៀនអំពីបច្ចេកវិជ្ជាជួយអ្នកពិការ (Assistive Technology)។<br>មិត្តភក្តិម្នាក់ត្រូវបានគេជ្រើសរើសឱ្យដឹកនាំកិច្ចប្រជុំដើម្បីធានាឱ្យប្រាកដថា<br>អ្នកណាក៏ដោយដែលចង់និយាយអ្វីនឹងមានឱកាសនិយាយ។<br><br>▪ មិត្តភក្តិម្នាក់បានទទួលការហ្វឹកហ្វឺនដើម្បីធ្វើជាមេដឹកនាំផ្នែកការគាំទ្រមិត្តភក្តិ (Peer Support)។ |

| | |
|---|---|
| | ឥឡូវនេះអ្នកស្រី/កញ្ញាកំពុងជួយមិត្តភក្តិថ្មីៗឱ្យរៀនអំពីការគាំទ្រមិត្តភក្តិ។ |

## 3. Peer Movement

| សេចក្តីបកប្រែ | ចលនាមិត្តភក្តិ |
|---|---|
| ការពន្យល់ខ្លីៗពីអត្ថន័យ | មិត្តភក្តិ និងសម្ព័ន្ធមិត្ត សហការគ្នា ហើយចាត់វិធានការណ៍ដើម្បីធ្វើការផ្លាស់ប្តូរអ្វីៗឱ្យវាបានប្រសើរ។ មិត្តភក្តិជួបជុំគ្នាហើយនិយាយថា៖ “គ្មានអ្វីដែលពាក់ព័ន្ធដល់យើងអាចប្រព្រឹត្តទៅបានដោយគ្មានការចូលរួមពីយើងទេ”។ |
| ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រើប្រាស់ពាក្យនេះ | ▪ មិត្តភក្តិមួយក្រុម និងសម្ព័ន្ធមិត្តរបស់ខ្លួនជួបជុំគ្នាដើម្បីតវ៉ាអំពីការខ្វះច្រកទ្វារសំរាប់ជនពិការចូលទៅក្នុងរោងកុនថ្មីមួយ។<br>▪ មិត្តភក្តិមួយក្រុម និងសម្ព័ន្ធមិត្តរបស់ខ្លួនជួបជុំគ្នាដើម្បីរៀបចំបទបង្ហាញមួយយកទៅនិយាយនៅក្នុងសន្និសិទ្ធអំពីបទពិសោធន៍ និងចំណេះដឹងរបស់ខ្លួន។ |

## 4. Peer Mentor

| | |
|---|---|
| សេចក្តីបកប្រែ | មិត្តភក្តិណែនាំ |
| ការពន្យល់ខ្លីៗពីអត្ថន័យ | មិត្តភក្តិណែនាំ គឺជាជនម្នាក់ដែលមានជំនាញ<br>ឬចំណេះដឹងដែលខ្លួនគេអាចចែករំលែកជាមួយមិត្តភក្តិម្នាក់ទៀត<br>មួយទល់នឹងមួយ។<br>ម្នាក់ៗពូកែខាងអ្វីមួយ<br>ដូច្នេះម្នាក់ៗអាចធ្វើជាមិត្តភក្តិណែនាំបាន។ |
| ឧទាហរណ៍ខ្លះៗ<br>បង្ហាញពីការប្រើប្រាស់<br>ពាក្យនេះ | ▪ អ្នកស្រី/កញ្ញា**សុភា**ដឹងច្រើនអំពីការគ្រប់គ្រងដោយខ្លួនឯង។<br>អ្នកស្រី/កញ្ញាជួបជាមួយលោក**ឧត្តម**រៀងរាល់ខែហើយជួយគាត់<br>ឱ្យចេះគ្រប់គ្រងប្រាក់ NDIS បានកាន់តែប្រសើរឡើង។<br>គាត់ទាំងពីរនាក់នឹងធ្វើការនេះចំនួនបីខែ<br>ហើយបន្ទាប់មកគេនិពិនិត្យមើលថាតើ<br>លោក**ឧត្តម**នៅតែត្រូវការឱ្យអ្នកស្រី/កញ្ញា**សុភា**ជួយឬទេ។<br><br>▪ លោក**បាន**ពូកែខាងគ្រប់គ្រងប្រាក់កាសរបស់ខ្លួន។<br>គាត់មានប្រព័ន្ធមួយដែលល្អសំរាប់គាត់។<br>គាត់ជួបលោក**ចន**ពីរបីដង<br>ហើយបង្ហាញលោក**ចន**អំពីប្រព័ន្ធនេះ។ |

## 5. Peer Network

| សេចក្ដីបកប្រែ | បណ្ដាញមិត្តភក្តិ |
|---|---|
| ការពន្យល់ខ្លីៗពីអត្ថន័យ | ទំនាក់ទំនងដែលមិត្តភក្តិមានទៅវិញទៅមក។<br>មិត្តភក្តិមួយក្រុមដែលរក្សាទំនាក់ទំនងទៅវិញទៅមក (តាមរយៈកិច្ចប្រជុំ តាម<br>ឬតាមទូរសព្ទ)។ |
| ឧទាហរណ៍ខ្លះៗ<br>បង្ហាញពីការប្រើប្រាស់ពាក្យនេះ | ▪ជនពិការមួយក្រុមជួបជុំគ្នាមួយខែម្ដងនៅក្នុងហាងកាហ្វេមួយ<br>និងនិយាយអំពីបញ្ហាផ្លូវចូលសំរាប់កៅអីរុញក្នុងតំបន់<br>ហើយត្រូវធ្វើដូចម្ដេចអំពីបញ្ហាទាំងនោះ។<br>▪មិត្តភក្តិបីនាក់ដែលមានចំណូលចិត្តស្រដៀងគ្នាក្នុងការលេងល្បែងកំសាន្តតា<br>(online gaming) ហើយគេជួបគ្នាតាមអ៊ីនធើណិត<br>រៀងរាល់សប្ដាហ៍ដើម្បីលេងល្បែងកំសាន្តខ្លះៗជាមួយគ្នា និងចែករំលែកនូវគន្លឹ<br>និងល្បិចទៅវិញទៅមក។ |

## 6. Peer Support

| សេចក្ដីបកប្រែ | ការគាំទ្រមិត្តភក្តិ |
|---|---|
| ការពន្យល់ខ្លីៗពីអត្ថន័យ | ការចាំជួយមិត្តភក្តិម្នាក់ទៀត ពេលគេត្រូវការជំនួយ។<br>ការជួយមិត្តភក្តិម្នាក់ទៀត។ |

| | |
|---|---|
| ឧទាហរណ៍ខ្លះៗ<br>បង្ហាញពីការប្រើប្រាស់ពាក្យនេះ | ▪ លោក**លឹម** ជួយលោក**វីរៈ**សរសេរសំបុត្រប្តឹងតវ៉ា (complaint letter)<br>▪ អ្នកស្រី**សុវណ្ណ**ជួយលោក**ឆៃរី**ធ្វើសម្ភាសន៍បុគ្គលិកថ្មី។ |

**7. Peer Support Group**

| | |
|---|---|
| សេចក្តីបកប្រែ | ក្រុមគាំទ្រមិត្តភក្តិ |
| ការពន្យល់ខ្លីៗពីអត្ថន័យ | មិត្តភក្តិមួយក្រុមជួយគ្នាទៅវិញទៅមក។<br>ក្រុមនេះអាចជួបទល់មុខគ្នា ឬតាមរយៈអ៊ីនធើណិត ឬតាមទូរសព្ទ។ |
| ឧទាហរណ៍ខ្លះៗ<br>បង្ហាញពីការប្រើប្រាស់ពាក្យនេះ | មិត្តភក្តិមួយក្រុមជួបជុំគ្នាដើម្បីនិយាយអំពីការធ្វើដំណើរទៅប្រទេសក្រៅ និងថាត្រូវធ្វើដូចម្តេច។ ពួកគេចែករំលែកបទពិសោធន៍ និងរឿងរ៉ាវរបស់ខ្លួន។ |

**8. Peer Leadership**

| | |
|---|---|
| សេចក្តីបកប្រែ | ភាពជាមេដឹកនាំលើមិត្តភក្តិ |
| ការពន្យល់ខ្លីៗពីអត្ថន័យ | មិត្តភក្តិណាម្នាក់អាចជាមេដឹកនាំ។<br>ភាពជាមេដឹកនាំលើមិត្តភក្តិកើតមានឡើងនៅពេលដែលមិត្តភក្តិម្នាក់ ឬមិត្តភក្តិ |

| | |
|---|---|
| | |
| ឧទាហរណ៍ខ្លះៗ<br>បង្ហាញពីការប្រើប្រាស់ពាក្យនេះ | ▪ក្រុមគាំទ្រមិត្តភក្តិថ្មីមួយក្នុងតំបន់ដឹកនាំដោយលោក**តូនី** និងអ្នកស្រី/កញ្ញា**លី**<br>លោក**វិជ្ជ**ឥឡូវនេះកំពុងដើរតួជាមេដឹកនាំដោយទទួលខុសត្រូវខាងទូរសព្ទទៅរំ<br><br>▪អំណាចមិត្តភក្តិ (peer power)<br>គឺជាព្រឹត្តិការណ៍មួយដែលត្រូវបានរៀបចំឡើងដោយមេដឹកនាំពីរបីនាក់ដើម្បីឱ្យ |

**9. Accountability**

| សេចក្ដីបកប្រែ | ភាពទទួលខុសត្រូវ |
|---|---|
| ការពន្យល់ខ្លីៗពីអត្ថន័យ | អ្នកអាចទុកចិត្តខ្ញុំបាន។<br>បើខ្ញុំនិយាយថា ខ្ញុំនឹងធ្វើអ្វីមួយ នោះខ្ញុំនឹងធ្វើវា។<br>ហើយបើអ្នកនិយាយថាអ្នកនឹងធ្វើអ្វីមួយ<br>ខ្ញុំនឹងទុកចិត្តអ្នក និងពឹងផ្អែកលើអ្នក។ |
| ឧទាហរណ៍ខ្លះៗ<br>បង្ហាញពីការប្រើប្រាស់ពាក្យនេះ | .បើសិនអ្នករៀបចំកិច្ចប្រជុំមួយ<br>នោះអ្នកនឹងមកចូលរួមទាន់ពេលវេលា។<br><br>▪ខ្ញុំនិយាយថា ខ្ញុំនឹងរៀបចំអ្វីមួយ<br>ហើយខ្ញុំបានធ្វើមែន។ |

| | |
|---|---|
| | . ខ្ញុំទូរសព្ទទៅអ្នកដោយហេតុថា អ្នកបាននិយាយថាអ្នកនឹងរៀបចំកិច្ចការនេះឱ្យហើយមុនសប្តាហ៍កន្លងទៅ តែអ្នកមិនបានធ្វើវាទេ។ |

## 10. Paying It Forward

| | |
|---|---|
| សេចក្តីបកប្រែ | ការឲ្យគេអ្វីមួយដោយមិនចង់បានអ្វីមកវិញ (Paying It Forward) |
| ការពន្យល់ខ្លីៗពីអត្ថន័យ | អ្នកឲ្យអ្វីមួយដោយឥតគិតថ្លៃ ហើយពុំចង់បានអ្វីតបមកវិញទេ។ ជនម្នាក់បានជួយអ្នក ហើយឥឡូវនេះអ្នកចង់ជួយអ្នកដ៏ទៃ។ |
| ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រើប្រាស់ពាក្យនេះ | . មិត្តភក្តិម្នាក់ដែលបានទទួលអត្ថប្រយោជន៍ពីការដែលគេជួយ មានអារម្មណ៍ថាចង់ក្លាយទៅជាមិត្តណែនាំម្នាក់(Peer Mentor)ដើម្បីឲ្យគាត់(អ្នកស្រី/កញ្ញា)ឥឡូវនេះអាចជួយអ្នកដ៏ទៃដែរ។<br>. អ្នកទៅចូលរួមកិច្ចប្រជុំមួយរបស់ក្រុមគាំទ្រមិត្តភក្តិ (peer support group) ដោយហេតុថា អ្នកមានព័ត៌មានខ្លះៗដែលអ្នកដឹងហើយដែលមានប្រយោជន៍ដល់ជនដ៏ទៃ។ |

## 11. To be humble

| សេចក្តីបកប្រែ | ភាពដាក់ខ្លួន |
| --- | --- |
| ការពន្យល់ខ្លីៗពីអត្ថន័យ | អ្នកដឹងខ្លួនថាអ្នកជានរណា ហើយអ្នកប្រហែលជាពូកែខាងអ្វីមួយ។ ប៉ុន្តែអ្នកមិនបង្អួតគេ ឬអួតអាងទេ។ អ្នកពុំក្រអឺតក្រទមទេ។ លោកអ្នកពូកែខាងធ្វើឱ្យអ្នកដ៏ទៃមានអារម្មណ៍ថាអ្នកស្មើនឹងគេដែរ។ |
| ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រើប្រាស់ពាក្យនេះ | . អ្នកត្រូវបានគេស្នើសុំឱ្យធ្វើអ្វីមួយដែលអ្នកពូកែ ហើយដែលអ្នកចូលចិត្តធ្វើ។ ប៉ុន្តែអ្នកដឹងថា មានជនដ៏ទៃទៀតនៅក្នុងក្រុមដែលធ្វើកិច្ចការនេះបាន ដូច្នេះអ្នកដកខ្លួនថយ ហើយធ្វើឱ្យប្រាកដថា ជនម្នាក់ផ្សេងមានឱកាសធ្វើកិច្ចការនេះ។<br><br>. ជនម្នាក់សរសើរអ្នក។ អ្នកអរគុណគេ ហើយធ្វើឱ្យប្រាកដថា ជនគ្រប់រូបក្នុងក្រុមដែលបានជួយក៏បានទទួលការនូវការសរសើរខ្លះដែរ។ |

## 12. Ally

| | |
|---|---|
| សេចក្តីបកប្រែ | សម្ព័ន្ធមិត្ត |
| ការពន្យល់ខ្លីៗពីអត្ថន័យ | សម្ព័ន្ធមិត្តម្នាក់ (Ally) មិនមែនជាមិត្តភក្តិ (peer) ទេ ប៉ុន្តែគេជាអ្នកគាំទ្រម្នាក់។ គេជាផ្នែកមួយនៃចលនាមិត្តភក្តិ (peer<br>movement)ហើយធ្វើការរួមគ្នាជាមួយមិត្តភក្តិដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ។ សម្ព័ន្ធមិត្តធ្វើតាមការដឹកនាំរបស់មិត្តភក្តិ។ |
| ឧទាហរណ៍ខ្លះៗ បង្ហាញពីការប្រើប្រាស់ពាក្យនេះ | . អ្នកស្រី/កញ្ញា**អានី**បានរាប់អានលោក**ថៃម**ជាមិត្តរយៈពេលយូរមកហើយ។<br>អ្នកស្រី/កញ្ញាបានចូលរួមកិច្ចប្រជុំនៃក្រុមគាំទ្រមិត្តភក្តិ (Peer Support)<br>ហើយបានជួយលោក**ថៃម**ក្នុងការបញ្ចេញមតិរបស់ខ្លួន។<br><br>.<br>លោក**ប៉ូឡូ**ជាអ្នកធ្វើការស្ម័គ្រចិត្តម្នាក់នៅមជ្ឈមណ្ឌលផ្តល់កិច្ចបំរើក្នុងតំបន់មួយ។ រៀងរាល់ពេលដែលក្រុមមិត្តភក្តិ (peer group) ជួបជុំគ្នា គាត់បើកសាលប្រជុំ<br>ហើយរៀបចំកៅអីរួចជាស្រេច។<br>គាត់ក៏ជួយដែរនៅពេលកិច្ចប្រជុំចប់។ |

## 13. Reflection

| សេចក្ដីបកប្រែ | ការជញ្ជឹងគិត |
|---|---|
| ការពន្យល់ខ្លីៗពីអត្ថន័យ | ការគិតអំពីអ្វីដែលកើតឡើងកន្លងទៅ<br>ហើយធ្វើការផ្លាស់ប្ដូរអ្វីមួយដើម្បីធ្វើឱ្យវាប្រសើរឡើងនៅពេលក្រោយ។<br>ការជញ្ជឹងគិតអាចធ្វើតែម្នាក់ឯង<br>ឬទាំងអស់គ្នាជាមួយអ្នកដ៏ទៃ។ |
| ឧទាហរណ៍ខ្លះៗ<br>បង្ហាញពីការប្រើប្រាស់ពាក្យនេះ | បន្ទាប់ពីកិច្ចប្រជុំនៃក្រុមមិត្តភក្ដិមក<br>អ្នកអង្គុយជាមួយនឹងអ្នកសម្រួលកិច្ចការ(facilitator)<br>ហើយអ្នកជញ្ជឹងគិតអំពីអ្វីដែលបានកើតឡើងនៅពេលប្រជុំ។<br>សំនួរដែលអ្នកសួរគឺមាន៖<br>**អ្វី** ...ដែលដំណើរការល្អ/មិនដំណើរការល្អ?<br>**ដូច្នេះអ្វី**...ដែលយើងអាចផ្លាស់ប្ដូរបាននិងធ្វើខុសពីមុន?<br>**ឥឡូវនេះអ្វី**...ដែលយើងត្រូវធ្វើនៅចន្លោះពេលឥឡូវទៅដល់ពេលប្រជុំលើកក្រោយ។ |

## 14. Confidentiality

| សេចក្ដីបកប្រែ | ការសម្ងាត់ |
|---|---|

| | |
|---|---|
| ការពន្យល់ខ្លីៗពីអត្ថន័យ | កិច្ចព្រមព្រៀងមួយស្ដីអំពីអ្វីដែលអាច និងអ្វីដែលមិនអាចចែករំលែកជាមួយអ្នកដ៏ទៃទៀតដែលពុំមែនជាភាគីនៃកិច្ចព្រមព្រៀង។ |
| ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រើប្រាស់ពាក្យនេះ | ក្រុមគាំទ្រមិត្តភក្តិ (peer support group) មួយបានធ្វើកិច្ចព្រមព្រៀងមួយនេះស្ដីអំពីការរក្សាការសម្ងាត់ដូចតទៅ៖ អ្វីៗដែលបាននិយាយចេញមកអំពីជនណាម្នាក់នៅក្នុងក្រុមគឺជារឿងផ្ទាល់ខ្លួន និងមិនត្រូវនិយាយប្រាប់បន្តទៅជនដ៏ទៃទៀតនៅក្រៅក្រុមឡើយ។ |

## 15. I get you – factor

| | |
|---|---|
| សេចក្ដីបកប្រែ | ការមានអារម្មណ៍ក្នុងខ្លួនថាគេយល់ឬដឹងពីយើងហើយ |
| ការពន្យល់ខ្លីៗពីអត្ថន័យ | ការបានចែករំលែកបទពិសោធន៍ជាមួយអ្នកដ៏ទៃម្នាក់ ជារឿយៗនេះមានន័យថាជនម្នាក់នោះអាចយល់អ្នកបានយ៉ាងងាយ ហើយការនេះមានន័យថា អ្នកមិនចាំបាច់ពន្យល់អំពីខ្លួនឯងទេ។ |
| ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រើប្រាស់ពាក្យនេះ | មិត្តភក្តិមួយក្រុមចែករំលែកចំណេះដឹងនិងបទពិសោធន៍របស់ខ្លួនស្ដីអំពីការទៅជួបផដ្ឋបណ្ឌិតក្នុងតំបន់។ |

| | |
|---|---|
| | ម្នាក់ៗមានអារម្មណ៍ថាខ្លួនយល់ច្បាស់លាស់ព្រោះថាម្នាក់ៗចែករំលែកបទពិសោធន៍ស្រដៀងគ្នា។ |

## 16. Reciprocal / mutually beneficial

| | |
|---|---|
| សេចក្តីបកប្រែ | ការទទួលបានផលប្រយោជន៍ទាំងសងខាង |
| ការពន្យល់ខ្លីៗពីអត្ថន័យ | មនុស្សគ្រប់រូបមានអារម្មណ៍ថា ខ្លួនជាអ្នកឈ្នះម្នាក់។ វាជាការល្អសំរាប់ជនគ្រប់រូប។ ម្នាក់ៗបានទទួលផលប្រយោជន៍អ្វីមួយពីវា។ |
| ឧទាហរណ៍ខ្លះៗ បង្ហាញពីការប្រើប្រាស់ពាក្យនេះ | លោក**សែម** និងអ្នកស្រី/កញ្ញា**ចារីរី**ជួបគ្នាដើម្បីផឹកកាហ្វេ ហើយគេចែករំលែកនូវអ្វីដែលខ្លួនដឹងអំពីការជួលបុគ្គលិក។ ក្រោយមកគេមានអារម្មណ៍ថាម្នាក់ៗបានទទួលអត្ថប្រយោជន៍ទាំងសងខាងពីការជួបគ្នានោះ។ |

## 17. Advocacy

| | |
|---|---|
| សេចក្តីបកប្រែ | ការតស៊ូមតិ/ការគាំទ្រ |
| ការពន្យល់ខ្លីៗពីអត្ថន័យ | និយាយឱ្យគេដឹងអំពីអ្វីដែលសំខាន់។ |
| ឧទាហរណ៍ខ្លះៗ បង្ហាញពីការប្រើប្រាស់ពាក្យនេះ | ជនពិការជាច្រើនពុំអាចរកការងារធ្វើបានទេ។ អ្នកគាំទ្រមួយក្រុម (ជនដែលមានពិការភាព |

| | |
|---|---|
| | និងសម្ព័ន្ធមិត្ត) បានជួបជុំគ្នា ហើយបានរៀបចំយុទ្ធនាការមួយដើម្បីជួបជាមួយអ្នកនយោបាយក្នុងតំបន់ ហើយពិភាក្សាជាមួយគេស្តីអំពីបញ្ហានោះ។ |

## 18. Self-Advocacy Movement

| | |
|---|---|
| សេចក្តីបកប្រែ | ចលនាការតស៊ូមតិសំរាប់ខ្លួនឯង |
| ការពន្យល់ខ្លីៗពីអត្ថន័យ | អ្នកគាំទ្រខ្លួនឯងគឺជាអ្នកមានពិការភាព។<br>អ្នកគាំទ្រខ្លួនឯងជួបជុំគ្នា<br>ហើយចាត់វិធានការណ៍ដើម្បីផ្លាស់ប្តូរអ្វីៗដែលជាបញ្ហាសំខាន់។<br>អ្នកគាំទ្រខ្លួនឯងបានជួបជុំគ្នា ហើយនិយាយថា៖<br>"គ្មានអ្វីដែលពាក់ព័ន្ធដល់យើងអាចប្រព្រឹត្តទៅបានដោយគ្មានការចូលរួមពីយើងទេ" |
| ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រើប្រាស់ពាក្យនេះ | . អ្នកគាំទ្រខ្លួនឯងបានជួបជុំគ្នា<br>ហើយតវ៉ាអំពីការខ្វះផ្លូវសំរាប់ជនពិការចូលទៅក្នុងរោងកុនថ្មីមួយ។<br><br>. អ្នកគាំទ្រខ្លួនឯងបានជួបជុំគ្នា<br>ហើយរៀបចំសន្និសិទ្ធមួយសំរាប់ជនដ៏ទៃទៀតដែលមានពិការភាពឱ្យយល់ដឹងអំពីសិទ្ធិរបស់ខ្លួននៅពេលទៅជួបវេជ្ជបណ្ឌិត។ |